បទអន្តរាគមន៍
របស់ឯកឧត្តមទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី
នគរូបនីយកម្ម និងសំណង់ ក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣
(ថ្ងៃទី ២-៣ ខែ មិថុនា ឆ្នាំ ២០១០ នៅក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា )

**– សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**– ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**– ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ តំណាងដៃគូរអភិវឌ្ឍន៍ និង អង្គការសង្គមស៊ីវិល**

ក្នុងនាមរាជរដ្ឋាភិបាល និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខ្ញុំសូមលើកឡើងដោយសង្ខេបនូវព័ត៌មានពាក់ព័ន្ធនឹងការងារសំខាន់ៗមួយចំនួន ដែលរាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងអនុវត្ត ទទួលបានលទ្ធផលជាវិជ្ជមានក្នុងទិសដៅលើកស្ទួយ និងការការពារសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋ និងសហគមន៍ជនជាតិដើមភាគតិច ដើម្បីជាការបកស្រាយបំភ្លឺផងដែរជូនអង្គប្រជុំ ទាក់ទងនឹងការលើកឡើងនៅក្នុងរបាយការណ៍ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាល អំពីការងារដីធ្លី ដូចតទៅ :

- អំពីការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ : រាជរដ្ឋាភិបាលអនុវត្តទៅតាមបទដ្ឋានគតិយុត្ត គឺធ្វើការចុះបញ្ជីដីជាទូទៅ ទាំងដីអ្នកមាន អ្នកក្រ និងដីរបស់ជនងាយរងគ្រោះដទៃទៀត ដែលកាន់កាប់ដោយស្របច្បាប់ ហើយការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនេះ គឺធ្វើឡើង១ភូមិម្តងៗ ដោយស្មើភាពគ្នាចំពោះមុខច្បាប់ និងមិនមានការរើសអើងឡើយ។ មកទល់ពេលនេះ ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធកំពុងធ្វើនៅរាជធានី ខេត្តចំនួន ១៦ ស្រុក ក្រុងចំនួន ៥០ ឃុំ សង្កាត់ចំនួន ២៧៥ និងភូមិចំនួន ២.៣២១ ភូមិ ហើយលទ្ធផលសម្រេចបានរួមមាន : ប្រមូលទិន្នន័យដីបានជិត ១.៩០០.០០០ក្បាលដី និងចែកប័ណ្ណដល់ម្ចាស់ដីបានចំនួនជាង ១.៣០០.០០០ប័ណ្ណ។ ដោយឡែកការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបានចំនួនជិត ៦០០.០០០ ក្បាលដី។ ដូច្នេះសរុបប័ណ្ណទាំង២ប្រភេទដែលបានចែករួចហើយមានជិត ២ លានប័ណ្ណ។ នេះជាលទ្ធផលនៃការខិតខំរបស់រាជរដ្ឋាភិបាល ដែលមិនអាចកាត់ផ្តាច់បានពីការជួយសហការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមយ៉ាងសកម្មរបស់ម្ចាស់ដី ដែលធ្វើឱ្យសំរេចបានលទ្ធផលនេះ ។

- អំពីការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ៖ ទាក់ទងនឹងការងារនេះ ឆ្លងតាមលទ្ធផលដែលសំរេចបានកន្លងមក ក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច និងគំរោងការងារសំរាប់រយៈពេលខាងមុខ សហគមន៍សភាអន្តរជាតិ(IPU)បានទទួលស្គាល់ និងកោតសរសើរការងារដែលរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំអនុវត្តលើកស្ទួយសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចដែលមាននៅក្នុងប្រទេសកម្ពុជា។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងរៀបចំបង្កើតនិងបណ្តុះបណ្តាលក្រុមការងារចុះបញ្ជីថ្នាក់ខេត្ត ដើម្បីបន្តចុះបញ្ជីដីជូនបងប្អូនសហគមន៍ជនជាតិដើមភាគតិច ជាពិសេសក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចទាំង ៧ ដែលបាននិងកំពុងរៀបចំបែបបទ ដើម្បីបានការទទួលស្គាល់តាមផ្លូវច្បាប់ ។
- ពាក់ព័ន្ធនឹងការផ្តល់សម្បទានដីសង្គមកិច្ច ក្រោមការចង្អុលបង្ហាញពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលកំពុងជំរុញយ៉ាងសកម្ម ការរៀបចំកម្មវិធីបែងចែកដីធ្លីក្នុងក្របខ័ណ្ឌសម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋស៊ីវិល អតីតកងកំលាំងប្រដាប់អាវុធ និងគ្រួសារ ។ អនុវត្តនូវទិសដៅនេះ ដីធ្លីចំនួន ៤៩ ទីតាំងដែលមានទំហំ ១៣០.០០០ហិកតា ត្រូវបានធ្វើអត្តសញ្ញាណកម្ម ដោយប្រមូលទិន្នន័យបឋមរួចហើយ ដើម្បីបំរើកម្មវិធីនេះ ។ បច្ចុប្បន្ន ក្រុមការងារកំពុងធ្វើអត្តសញ្ញាណកម្មអ្នកត្រូវទទួលដី និងក្រុមការងារពិនិត្យ សិក្សាគុណភាពដីលំអិតជាក់ស្តែង កំពុងរៀបចំឯកសារយ៉ាងមមាញឹក ដើម្បីអាចចាប់ផ្តើមអនុវត្តកម្មវិធីនេះ នៅក្នុងឆ្នាំ ២០១១ ។
- ចំពោះការដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការ រាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងកែលំអយន្តការដោះស្រាយទំនាស់ដីធ្លី (គណៈកម្មការសុរិយោដី) ដោយបានផ្តល់ប្រតិភូកម្មដល់អជ្ញាធរថ្នាក់ខេត្ត ក្នុងការធ្វើសេចក្តីសម្រេច និងដោះស្រាយទំនាស់ដីធ្លីផងដែរ។

ដោយឡែក ជាការឆ្លើយតបទៅនឹងរបាយការណ៍ឯកសារស្តីពីជំហររបស់អង្គការមិនមែនរដ្ឋាភិបាលចំពោះការអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០០៩-២០១០ សម្រាប់វេទិកា CDCF លើកទី ៣ ក្រសួងស្វាគមន៍ការជួយមតិស្ថាបនាដោយស្មោះស តែចំពោះមតិរិះគន់ដែលបានលើកឡើងនៅក្នុងឯកសារ គឺប្រាសចាកការពិតផ្ទុយទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុង**ការអនុវត្តកម្មវិធីកំណែទម្រង់វិស័យដីធ្លី**។ ម្យ៉ាងទៀតពាក់ព័ន្ធនឹងករណីសិក្សា (Case Studies) នៅរាជធានីភ្នំពេញ និងទីប្រជុំជនដទៃទៀត ការលើកឡើងសង្កត់ធ្ងន់តែពីបញ្ហាសិទ្ធិមួយមុខប៉ុណ្ណោះ ដោយមិនបានពិចារណាពីការទទួលខុសត្រូវ និងការគោរពច្បាប់ទេ។ ម្យ៉ាងទៀតឯកសារនេះ ផ្អែកជាគោលទៅលើរបាយការណ៍របស់ក្រុមអង្គការក្រៅរដ្ឋាភិបាលទាំងស្រុង ដោយមិនបានសុំការពិគ្រោះយោបល់ពីស្ថាប័ន និងដៃគូអភិវឌ្ឍដែលជាអ្នកអនុវត្តផ្ទាល់ ។

សូមអរគុណ